ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ១១
ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤
សាលដីកា
លេខ : ០១
ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៦

# តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រម
៣- លោក វៀល មួន ចៅក្រម
៤- លោក យស់ សូខឿន ចៅក្រម
៥- លោក ស៊ិន ឌីម ចៅក្រម

ក្រឡាបញ្ជី

លោក **ឌឹម សទ្ធារិទ្ធិ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០១"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១១ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ពិរុទ្ធ*** : ប៉ុនប៉ងមនុស្សឃាដដោយគិតទុកជាមុន និង ក្រុមជនប្រដាប់អាវុធ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីឆ្នាំ១៩៩៧ .១៩៩៩ និង ឆ្នាំ ២០០០ ។

១-ជនជាប់ចោទឈ្មោះ គីម សេង ហៅ តាំង ឡេវជីវ ហៅ កិះ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩៣ ផ្លូវ១១១ សង្កាត់អូរឬស្សី១ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះអ៊ុង សាង "រ" ម្តាយឈ្មោះអ៊ី ជូ "រ" ប្រពន្ធឈ្មោះសាង គុណា មានកូន០១នាក់ ទោសពីមុនគ្មាន ។

-មានមេធាវីលោកសោម ច័ន្ទឌីណា

២-ជនជាប់ចោទឈ្មោះសាង គុណ ហៅ ជូ ( ជាចុងបណ្តឹងសាទុក្ខ ) ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥៣ ផ្លូវលេខ១១១ សង្កាត់អូរឫស្សី១ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះអ៊ុង សាង "ស" ម្តាយឈ្មោះប៉ាក ហួយ "រ" មានកូន០១នាក់ ទោសពីមុនគ្មាន ។

-មានមេធាវី លោក សោម ច័ន្ទឌីណា

-ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះប៉ោ សៀង ( ជាម្ចាស់បណ្តឹងសាទុក្ខ ) ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥១ ផ្លូវ៥៣ សង្កាត់ផ្សារថ្មីទី៤ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-មានមេធាវី លោក សែម ចិន្តា

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះប៉ោ សៀង បានបញ្ជាក់ថា កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០ វេលាម៉ោង១៥ និង ៣០នាទី ខ្លួនបានឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះជូ និង ប្តីឈ្មោះកិះ អ្នកលក់នាឡិកាដូចគ្នា ពេលនោះឈ្មោះកិះ បានគំរាមថា មិនអីទេចាំថ្ងៃស្អែកដឹងហើយ ។ លុះថ្ងៃស្អែកឡើងស្រាប់មានជនប្រដាប់អាវុធមួយក្រុមមានគ្នាពី៧ ទៅ៨នាក់ បានព័ទ្ធតូបរបស់ខ្លួន ហើយគំរាមរកសម្លាប់ពួកខ្លួនពីរនាក់ប្តីប្រពន្ធ ថាបើដូចពីមុនឯងដាច់ផ្ងារហើយ ស្របពេលនោះបងប្រុសខ្លួនបានមកដល់ ពួកវាក៏ចេញអស់ទៅ ។

-បានឃើញដីកាសំរេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-ហាមឃាត់ជនដែលត្រូវចោទទាំងអស់ ទាយាទជនជាប់ចោទព្រមទាំងអ្នកដទៃទៀត មិនអោយលក់ដូរ ផ្ទេរសិទ្ធិ ជួល បញ្ចាំ ឬ ធ្វើអំណោយដល់អ្នកដទៃនូវផ្ទះលេខ៥៣E₀ ផ្លូវ១១១ សង្កាត់អូរឫស្សី១ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ដែលមានវិញ្ញាបនប័ត្រលេខ២៣៩៥ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩១ ជាបណ្តោះអាសន្នរហូតដល់មានការសំរេចជាថ្មី ។

២-បង្គាប់មកមន្ត្រីមានសមត្ថកិច្ចទាំងអស់ដែលពាក់ព័ន្ធអនុវត្តដីកានេះឱ្យមានប្រសិទ្ធិភាពតាមច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះគីម សេង និងឈ្មោះសាង គុណ ប្តឹងមិនសុខចិត្តនឹងដីកាសំរេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ លើដីកាទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា : ក្នុងរឿងនេះជាបទព្រហ្មទណ្ឌ ពុំទាន់មានសាលក្រម ឬ សាលដីការបស់តុលាការចូលជាស្ថាពរណាមួយ ដែលសំរេចឱ្យជនជាប់ចោទសងសំណងទៅដើមបណ្តឹងឡើយ ។ ហើយតុលាការបែរជាចេញដីកាឃាត់ទ្រព្យសម្បត្តិរបស់ជនជាប់ចោទបែបនេះ មិនត្រឹមត្រូវទេ ដូចនេះមហាអយ្យការសំរេច :

+បដិសេធដីកាសំរេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអាសារបង់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០១"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះគីម សេង និង ឈ្មោះសាង គុណ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធដីកាសំរេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ចៅក្រមតុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-ទទួលពាក្យសុំដីកាសំរេច ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះប៉ោ សៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៤-សាលដីកានេះមានប្រសិទ្ធិភាព អនុវត្តភ្លាម ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារជនជាប់ចោទ និង មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

-បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះប៉ោ សៀង ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០១"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះប៉ោ សៀង (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះសាង គុណ និង គីម សេង (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : ក្រោយពីធ្វើការសិក្សាលើសំណុំរឿងរួចមក ឃើញថា បណ្តឹងសាទុក្ខរបស់ឈ្មោះប៉ោ សៀង ធ្វើឡើងពុំត្រឹមត្រូវតាមច្បាប់ ។ សាលដីកាសាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង សារណាការពាររបស់ឈ្មោះប៉ោ សៀង (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង សារណាតបរបស់ជនជាប់ចោទឈ្មោះគីម សេង ហៅតាំង ទៀវជីវ ហៅ កិះ (ជាចុងបណ្តឹងសាទុក្ខ) , ឈ្មោះសាង គុណ ហៅ ជូ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី សែម ចិន្តា ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះប៉ោ សៀង នៅពេលជំនុំជំរះថា : ក្នុងនាមខ្ញុំបាទជាមេធាវី ខ្ញុំសូមទាមទារយ៉ាងទទូច ចំពោះក្រុមប្រឹក្សាតុលាការកំពូល ដោយសូមឱ្យបដិសេធចោលនូវសាលដីកាលេខ០១"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ចោលទាំងស្រុង និង សូមតំកល់ដីកាសំរេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។ នៅក្នុងនីតិវិធីព្រហ្មទណ្ឌដើមបណ្តឹងអាចប្តឹងសុំទាំងពីរក៏បាន គឺទណ្ឌកម្ម និង សំណង ហើយតុលាការត្រូវសំរេចទាំងពីរ ប្រសិនបើជនជាប់ចោទរកឃើញថា មានកំហុស ហើយបណ្តាលឱ្យមានព្យសនកម្ម ។ ការដែលកូនក្តីខ្ញុំបាទ ប្តឹងសុំអោយឃាត់ទ្រព្យសម្បត្តិរបស់ជនល្មើសនោះ ព្រោះខ្លាចជនល្មើសរត់គេចខ្លួនបាត់ ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ម្យ៉ាងក៏មានសាលដីកាលេខ១៩ និង ២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានប្រសិទ្ធិភាពរួចទៅហើយ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាតុលាការកំពូលមេត្តាពិចារណាបន្ថែមទៅលើនីតិវិធីនេះ ព្រោះដីកាសំរេចរបស់តុលាការក្រុងភ្នំពេញ ដែលសំរេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសោម ច័ន្ទឌីណា ជាមេធាវីការពារឱ្យជនជាប់ចោទ នៅពេលជំនុំជំរះថា : ជាបឋមខ្ញុំបាទ សោម ច័ន្ទឌីណា ជាមេធាវីការពារឱ្យជនជាប់ចោទ ដែលត្រូវតុលាការក្រុងភ្នំពេញចោទប្រកាន់ពីបទ : ប៉ុនប៉ងមនុស្សឃាដដោយគិតទុកជាមុន និង ក្រុមជនប្រដាប់អាវុធ សូមគោរពឯកឧត្តមប្រធានក្រុមប្រឹក្សាទាំងមូល ។

តាមការលើកឡើងក្នុងសារណារបស់ឈ្មោះប៉ោ សៀង ខ្ញុំបាទសូមអនុញ្ញាតបង្ហាញជូននូវដំណើររឿងខ្លះៗ ជូនក្រុមប្រឹក្សាដូចតទៅ : រឿងក្តីនេះកើតឡើងរវាងឈ្មោះប៉ោ សៀង និង កូនក្តីខ្ញុំបាទពីរឿងមួយទិញនាឡិកា ដោយសារមានតូបនៅជិតគ្នា ហើយទំនាស់ក៏កាន់តែរីកធំបន្តិចម្តងៗ ដោយសារបញ្ហាអសន្តិសុខស្របពេលដែលមានឃាតករលបធ្វើឃាតខ្លួន ឈ្មោះប៉ោ សៀង ក៏យកលេសចោទទំលាក់កំហុសមកលើកូនក្តីខ្ញុំបាទតែម្តង តាមពិតឈ្មោះនេះធ្លាប់មានទំនាស់ជាមួយអ្នកផ្សេងៗជាច្រើន ។ ក្រោយពីកើតបញ្ហានេះ ឈ្មោះប៉ោ សៀង ក៏បានប្តឹងទៅតុលាការក្រុង ដោយសុំឱ្យឃាត់ផ្ទះកូនក្តីខ្ញុំបាទ ហើយតុលាការក្រុងភ្នំពេញក៏សំរេចចេញដីកាសំរេចលេខ៧១០៧ តព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ ដោយហាមឃាត់កូនក្តីខ្ញុំបានពុំឱ្យលក់ដូរ រឹបញ្ចាំ រឺផ្ទេរ ការសំរេចនេះមានការខុសឆ្គងយ៉ាងខ្លាំង ដោយបំពានទៅលើមាត្រាទី៤០ នៃរដ្ឋធម្មនុញ្ញ និង មាត្រាទី៥៧-៣៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល និង ច្បាប់ភូមិបាល ។

ខ្ញុំបាទសូមសំណូមពរបដិសេធដីកាសំរេចលេខ៧១០៧ ត.ព្រ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ និង តំកល់សាលដីកាលេខ០១"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកសែម ចិន្តា នៅពេលជំនុំជំរះថា : ច្បាប់រដ្ឋធម្មនុញ្ញបានការពារសិទ្ធិសេរីភាពបុគ្គលដូចៗគ្នា ចំពោះការស៊ើបធានការឃាមឃាត់របស់កូនក្តីខ្ញុំ ពុំធ្វើឱ្យប៉ះពាល់

ដល់ផលប្រយោជន៍របស់ជនជាប់ចោទ ពីព្រោះវាជាវិធានការចាំបាច់របស់នីតិវិធីច្បាប់ ដោយតុលាការកំពូលបានរកឃើញរួចទៅហើយនូវកំហុសឆ្គងនោះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកសោម ច័ន្ទឌីណា នៅពេលជំនុំជំរះថា : ចំពោះវិធានការដើម្បីគ្រប់គ្រងលើជនជាប់ចោទ គឺមានស្រាប់ទៅហើយ ។ ទី១ ជនជាប់ចោទត្រូវទទួលទណ្ឌកម្ម ហើយបើត្រូវចេញសំណងអំពីព្យសនៈកម្ម ប្រសិនបើមិនសងតុលាការត្រូវចាត់វិធានការតាមផ្លូវច្បាប់ ។ ដូចជាដាក់គុកបង្ខំលើរូបកាយជាដើម ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលនៅពេលសវនាការថា : ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមសំរេចតាមច្បាប់ចុះ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី សារណារបស់ជនត្រូវចោទ និង សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៤របស់អ្នកស្រីប៉ោ សៀង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ពុំទាន់មានសេចក្តីសំរេចណាមួយរបស់តុលាការ ដែលបានសំរេចផ្តន្ទាទោសជនត្រូវចោទជាបទអាជ្ញា ដែលមានលក្ខណៈស្ថាពរ ហើយតម្រូវអោយជនត្រូវចោទ សងព្យសនៈកម្មដល់ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីទេ ដូច្នេះការហាមឃាត់រាល់ការចាត់ចែងទ្រព្យសម្បត្តិរបស់ជនត្រូវចោទជាការពុំត្រឹមត្រូវទេ ។

-យល់ឃើញថា ការលើកឡើងរបស់អ្នកស្រីប៉ោ សៀង ក្នុងសារណាចុះថ្ងៃទីគ្មានខែគ្មានឆ្នាំ២០០៤ ទាមទារសុំឱ្យមានវិធានការបណ្តោះអាសន្នឃាត់ទ្រព្យសម្បត្តិមួយចំនួនរបស់ជនល្មើស ដោយអាងហេតុថាសាលដីកាតុលាការកំពូលលេខ១៩ និង លេខ២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២ មានប្រសិទ្ធិភាពអនុវត្តរួចហើយ នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាសាលដីកាព្រហ្មទណ្ឌលេខ១៩ និង លេខ២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូល ជាសាលដីកាសំរេចរឿងមុនអង្គសេចក្តី ពុំមែនជាសាលដីការឿងអង្គសេចក្តីស្ថាពរឡើយ ។

-យល់ឃើញថា ការដែលលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការមិនហាមឃាត់ការចាត់ចែងទ្រព្យសម្បត្តិរបស់ជនជាប់ចោទ និង ធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់កូនក្តីលោក

នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា ការបិតសិទ្ធិសេរីភាពជនណាមួយ ទោះជាលក្ខណៈបណ្ដោះអាសន្នក៏ដោយនឹងអាចធ្វើបាន នោះលុះណាតែតម្រូវការចាំបាច់បំផុតនៃប្រយោជន៍ច្បាប់ ឬ ជាប្រយោជន៍សន្តិសុខសាធារណៈប៉ុណ្ណោះ ។

-យល់ឃើញថា ទាំងជនជាប់ចោទ ទាំងដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើសារណាការពាររឿងក្ដីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្ដែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្ដែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០១"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីកំបាំងមុខជនជាប់ចោទ

## និង ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្ដែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ១១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៤ របស់អ្នកស្រីចៅ សៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្ដែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០១"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១១ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្ដី ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៦ ។